**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Aug-2013, 15:13
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់ ខៀវ សំផន**
**សុំផ្អាកកិច្ចដំណើរការនីតិវិធី**

---

| <u>អ្នកដាក់ឯកសារ:</u> | <u>អ្នកទទួលឯកសារ:</u> | <u>ចម្លងជូន:</u> |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះតុលាការកំពូល: | ជនជាប់ចោទ: |
| លោកស្រី ជា លាង | ចៅក្រម គង់ ស្រីម, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Motoo NOGUCHI | ខៀវ សំផន |
| | ចៅក្រម សោម សិរីវឌ្ឍ | |
| | ចៅក្រម C. N. JAYASINGHE | មេធាវីការពារក្តីជនជាប់ចោទ: |
| | ចៅក្រម ម៉ុង មុន្នីចរិយា | លោក សុន អរុណ |
| | ចៅក្រម យ៉ា ណារិន | លោក Victor KOPPÉ |
| | ចៅក្រម Florence Ndepele MUMBA | លោក គង់ សំអុន |
| | | លោកស្រី Anta GUISSÉ |
| | សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី: | លោក Athur VERKEN |
| | ពេជ អង្គ | |
| | Elisabeth SIMONNEAU FORT | |

## I. សេចក្ដីផ្ដើម និងប្រវត្តិនីតិវិធី

១- ក្រុមមេធាវីការពារក្ដី ខៀវ សំផន ("មេធាវីការពារក្ដី") បានដាក់សំណើមួយ[1]ថាអង្គជំនុំជម្រះនេះផ្អាកកិច្ចដំណើការនីតិវិធីជំនុំជម្រះក្ដីប្រឆាំងនឹងកូនក្ដីរបស់ខ្លួននៅក្នុងអង្គជំនុំជម្រះសាលាដំបូង ដែលចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើឱ្យខូចខាតដល់សិទ្ធិរបស់កូនក្ដីរបស់ខ្លួនដោយការរំលោភបំពានផ្សេងៗ។ តាមរយៈនេះ សហព្រះរាជអាជ្ញាធ្វើការឆ្លើយតប និងស្នើយោបល់ថា សំណើនេះមិនអាចទទួលយកបានទេ។

## II. បណ្ដឹងសាទុក្ខនេះមិនអាចទទួលយកបានទេ

២- ការដាក់ឯកសាររបស់មេធាវីការពារក្ដីនេះ មិនអាចទទួលយកបានទេ ពីព្រោះ៖ បណ្ដឹងសាទុក្ខនេះដាក់មកមិនទាន់ពេលវេលា ដោយហេតុថា កាលបរិច្ឆេទកំណត់សម្រាប់ការធ្វើបណ្ដឹងសាទុក្ខទៅនឹងសេចក្ដីសម្រេចជាច្រើនដែលមេធាវីការពារក្ដីជំទាស់នោះ បានសម្រេចត្រឹមត្រូវហើយមុនពេលមានសំណើនេះ។ មេធាវីការពារក្ដីមិនបានអនុវត្តតាមបន្ទុករបស់ខ្លួន ក្នុងការបង្ហាញឱ្យឃើញពីភាពអាចទទួលយកបានរបស់សំណើនេះ អនុលោមទៅតាមវិធាន១០៤(៤)នៃវិធានផ្ទៃក្នុងនោះឡើយ។ ហើយយុត្តិសាស្ត្រដែលជាជម្រើសផ្សេងទៀត ដែលមេធាវីការពារក្ដីបានលើកយកមកសម្អាងនោះ គឺមិនគាំទ្រចំពោះភាពអាចទទួលយកបាននៃសំណើរបស់ពួកគេ ក្នុងកាលៈទេសៈនេះឡើយ។

### ក. ការដាក់សំណើនេះ មិនទាន់ពេលវេលាកំណត់

៣- ដូចដែលបានពិភាក្សាបន្ថែមទៀត*ខាងក្រោមនេះ* មេធាវីការពារក្ដីមិនបានព្យាយាមដើម្បីធ្វើយុត្តិកម្មចំពោះភាពអាចទទួលយកបាននៃបណ្ដឹងសាទុក្ខរបស់ខ្លួនទាក់ទងនឹងវិធាន១០៤(៤)នៃវិធានផ្ទៃក្នុងទេ។ ហេតុដូចនេះគឺមិនអាចកំណត់ថា ប្រសិនបើគេតម្រូវឱ្យដាក់បណ្ដឹងសាទុក្ខរបស់ខ្លួន នៅក្នុងរយៈពេលយ៉ាងយូរដប់ប្រាំថ្ងៃតាមវិធាន១០៤(៤)(ខ) ឬ(គ)ជាធរមាន ឬមួយក៏ក្នុងរយៈពេលសាមសិបថ្ងៃយ៉ាង

[1] ឯកសារលេខ **E275/2/1/1** សំណើបន្ទាន់របស់ក្រុមមេធាវីការពារក្ដីលោក ខៀវសំផន សុំឱ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម, ចុះថ្ងៃទី១ ខែសីហាឆ្នាំ២០១៣ [សេចក្ដីបកប្រែជាភាសាអង់គ្លេសបណ្ដោះអាសន្ន] ( ដែលជាបន្តទៅទៀតក្នុងនេះហៅកាត់ថា "សំណើ")។ ដែលបានជូនដំណឹងនៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៣។

យូរទៅតាមវិធាន១០៤(៤)(ក) ឬ(ឃ)ជាធរមាននោះ។ ប៉ុន្តែបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី គឺធ្វើមិនទាន់ពេលវេលា។ មេធាវីការពារក្តីបានដាក់បណ្តឹងសាទុក្ខភ្លាមៗកាលពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣ ដែលអនុញ្ញាតឲ្យពួកគេលើកឡើងនូវការទាមទារមួយចំនួន និងជាអតិបរិមា ដើម្បីប្រឆាំងនឹងសេចក្តីសម្រេចនានាដែលបានជូនដំណឹងកាលពីថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៣។ ទោះជាយ៉ាងណាក៏ដោយ ក្នុងពេលដាក់សារណារបស់ខ្លួននោះ មេធាវីការពារក្តីរិះរក ដើម្បីជំទាស់នឹងសេចក្តីសម្រេចដែលបានធ្វើឡើង *ក្នុងចំណោមសេចក្តីសម្រេចផ្សេងៗទៀតជាច្រើន,* នៅក្នុងខែមិថុនា ឆ្នាំ២០១៣[2], ខែមេសា ឆ្នាំ២០១៣[3] និងក្នុងខែមេសា ឆ្នាំ២០១២[4]។ នៅត្រង់ចំណុចមួយ មេធាវីការពារក្តីក៏បានទទួលស្គាល់ផងដែរថាខ្លួនបានលើកសម្អាងដដែលជូនអង្គជំនុំជម្រះនេះ នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៣[5]។ លើសពីនេះទៅទៀត ការបិទកិច្ចដំណើរការសួរដេញដោលលើភ័ស្តុតាង នៅក្នុងសវនាការ មិនបានផ្តល់ដល់ភាគីនានានូវឱកាសដើម្បីធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចណាមួយ ដែលខ្លួនមិនបានយល់ព្រមនោះឡើយ នៅក្នុងពេលកំពុងដំណើរការជំនុំជម្រះក្តី ហើយហេតុនេះកាលបរិច្ឆេទនេះគឺមិនជាប់ទាក់ទងទៅនឹងគោលបំណង ក្នុងការកំណត់អំពីភាពទាន់ពេលវេលានៃសំណើនេះឡើយ។ អាស្រ័យហេតុនេះ សំណើរបស់មេធាវីការពារក្តី គឺមិនទាន់ពេលវេលា។

## ខ. ការដាក់សំណើនេះ មិនអាចទទួលយកបានទេ អនុលោមតាមវិធានផ្ទៃក្នុង

៤- ការដាក់សំណើរបស់មេធាវីការពារក្តី ខកខានមិនបានបំពេញទៅតាមលក្ខខណ្ឌតម្រូវនានាសម្រាប់ការទទួលយកឡើយ ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ឬទៅតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះនេះ។ មេធាវីការពារក្តីក៏មិនបានព្យាយាមដើម្បីលើកអំណះអំណាងថាខ្លួនបានព្យាយាមដែរ។ មេធាវីការពារក្តីមិនបានព្យាយាមធ្វើយុត្តិកម្មភាពអាចទទួលយកបាននៃការដាក់សំណើរបស់ខ្លួន តាមវិធាន១០៤នៃវិធានផ្ទៃក្នុង ដែលគ្រប់គ្រងលើ “សេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះសាលាដំបូងចំពោះការប្តឹងសាទុក្ខភ្លាមៗ” នោះដែរ ហើយតាមការពិត គឺខកខានមិនបានលើកយោងទៅលើវិធាន១០៤(៤) នៃវិធានផ្ទៃក្នុង នៅកន្លែងណាមួយនៃសំណើរបស់ខ្លួនដែរ។ មេធាវីការពារក្តីក៏បានខំប្រឹងយ៉ាងខ្លាំងក្លា

---

[2] ឯកសារលេខ **E275/2/1/1** សំណើ, ត្រង់កថាខណ្ឌលេខ ១០,៣៤,៣៦, ៨៥ ៨៦ និង៩២។

[3] ឯកសារលេខ **E275/2/1/1** សំណើ, ត្រង់កថាខណ្ឌលេខ ៥៨, និង ៦០។

[4] ឯកសារលេខ **E275/2/1/1** សំណើ, ត្រង់កថាខណ្ឌលេខ ៥៦ និង ៨០។

[5] ឯកសារលេខ **E275/2/1/1** សំណើ, ត្រង់កថាខណ្ឌលេខ ៦៣ និង ៦៤។

ផងដែរ ដើម្បីជៀសវាងនូវយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះនេះ ដែលបានសម្រេចដដែលៗ ថាបណ្តឹងសាទុក្ខលើបញ្ហាបន្ទាន់បង្ខំត្រូវបានកម្រិតត្រឹមតែមូលហេតុទាំងឡាយ ដូចដែលមានចែងនៅក្នុងវិធាន ១០៤(៤)នៃវិធានផ្ទៃក្នុងតែប៉ុណ្ណោះ។

៥- វិធាន១០៤(៤)នៃវិធានផ្ទៃក្នុង បានគូសបញ្ជាក់ពីនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចំនួន៤ប្រភេទដែល "ត្រូវប្តឹងសាទុក្ខភ្លាមៗ"។ ការដាក់សំណើរបស់មេធាវីការពារក្តី គឺមិនថិតនៅក្នុងប្រភេទដែលអនុញ្ញាតឲ្យធ្វើបណ្តឹងសាទុក្ខនោះឡើយ ហើយដែលកន្លងមក អង្គជំនុំជម្រះនេះធ្លាប់បានបដិសេធលើបណ្តឹងសាទុក្ខទាំងនេះថា "ខកខានមិនបានបំពេញទៅតាមលក្ខខណ្ឌតម្រូវនានាសម្រាប់ការប្តឹងសាទុក្ខភ្លាមៗដូចដែលមានចែងនៅក្នុងវិធាន១០៤(៤)នៃវិធានផ្ទៃក្នុង"[6] ។ ដូចដែលអង្គជំនុំជម្រះនេះធ្លាប់បានសម្រេចកាលពីមុនមកហើយថា៖

> យុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការធ្វើសវនាការលើបណ្តឹងសាទុក្ខ គឺត្រូវបានគ្រប់គ្រងដោយវិធាន១០៤នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះនេះ កន្លងមក បានរកឃើញថា យុត្តាធិការរបស់ខ្លួនក្នុងការពិនិត្យពិចារណាលើបណ្តឹងសាទុក្ខភ្លាមៗ គឺត្រូវបាន "កម្រិតបន្ថែមទៀត" ដោយវិធាន១០៤(៤) នៃវិធានផ្ទៃក្នុង ហើយហេតុដូចនេះ <u>សេចក្តីសម្រេចទាំងឡាយដែលមិនស្ថិតនៅក្នុងវិសាលភាពនៃវិធាន១០៤(៤) អាចឲ្យប្តឹងសាទុក្ខ</u>

[6] ឯកសារលេខ **E154/1/1/4** សេចក្តីសំរេចលើបណ្តឹងសាទុក្ខរបស់ អៀង សារីប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការប្រាស្រ័យទាក់ទងការងារជាមួយតែភាគីម្ខាងរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២, ត្រង់កថាខណ្ឌទី១៦។ *សូមអានផងដែរ* ឯកសារលេខ **E62/3/10/5/1** សេចក្តីសម្រេចលើសេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខរបស់មេធាវីនាំមុខនៃភាគីដើមបណ្តឹងរដ្ឋប្បវេណី, ចុះថ្ងៃទី២០ខែកញ្ញា ឆ្នាំ ឆ្ន២០១១, ត្រង់ទំព័រ២ (ករណីបើសិនជា "ក្នុងករណីការដាក់ឯកសារនេះចង់បង្ហាញដើម្បីធ្វើឲ្យបណ្តឹងសាទុក្ខនេះមានប្រសិទ្ធភាពដែលមិនអាចទទួលយកបានក្រោមវិធាន១០៤(៤)នៃវិធានផ្ទៃក្នុង")។ ឯកសារលេខ **E130/4/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចដែលតម្រូវឲ្យរូបគាត់មានវត្តមាននៅក្នុងសវនាការ, ចុះថ្ងៃទី១៣ ខែមករាឆ្នាំ២០១២, ត្រង់ទំព័រ២ (ដែលច្រានចោលភាពអាចទទួលយកបានក្នុងករណីបើសិនជា "ខ្លឹមសារនៃបណ្តឹងសាទុក្ខមិនស្ថិតនៅក្រោមយុត្តាធិការដែល មានកម្រិតរបស់អង្គជំនុំជម្រះលើបណ្តឹងសាទុក្ខភ្លាមៗដែលនៅក្រោមវិធាន១០៤(៤)នៃវិធានផ្ទៃក្នុង")។ សេចក្តីសម្រេចលើសេចក្តីជូនដំណឹងពីរនៃបណ្តឹងសាទុក្ខដែលដាក់ដោយ អៀង សារី ។ ឯកសារលេខ **E163/5/1/13** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលទាក់ទងអំពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១, ចុះថ្ងៃទី៨ កុម្ភៈ ២០១៣, ត្រង់កថាខណ្ឌទី១២ (ដែលកត់សម្គាល់អំពីបញ្ហាចំនួនបួនដែលជាកម្មវត្ថុនៃការប្តឹងសាទុក្ខភ្លាមៗតាមវិធាន១០៤(៤), ហើយដែលសម្រេចថា "[] សេចក្តីសម្រេចផ្សេងទៀតអាចប្តឹងសាទុក្ខបាននៅក្នុងពេលទន្ទឹមគ្នា ក្នុងនាមជាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើអង្គសេចក្តី តែប៉ុណ្ណោះ។ ឯកសារលេខ **E189/3/1/8** សេចក្តីសម្រេចលើ " បណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីពាក្យសុំឲ្យធ្វើចំណាត់ការបន្ទាន់អនុលោមតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង", ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១៣, ត្រង់កថាខណ្ឌទី១២(ដូចគ្នា)។

បាន តែបន្ទាប់ពីការចេញសាលក្រមចុងក្រោយប៉ុណ្ណោះ។ សេចក្ដីសម្រេចផ្សេងៗទៀត បានបដិសេធបណ្ដឹងសាទុក្ខស្រដៀងគ្នានេះដែរ ថាមិនអាចទទួលយកបាន ពីព្រោះបណ្ដឹងសាទុក្ខទាំងនេះមិនស្ថិតនៅក្នុងវិសាលភាពនៃវិធាន១០៤(៤)នៃវិធានផ្ទៃក្នុងឡើយ។ អាស្រ័យហេតុនេះ អំណះអំណាងអំពីភាពអាចទទួលយកបានរបស់មេធាវីការពារក្ដីដែលបានធ្វើឡើងដោយអនុលោមតាមវិធានផ្សេងទៀតនៃវិធានផ្ទៃក្នុង គឺត្រូវបានច្រានចោល[7]។

៦- អាស្រ័យហេតុនេះ ការដាក់សំណើនេះ គឺមិនអាចទទួលយកថាជាបណ្ដឹងសាទុក្ខភ្លាមៗបានឡើយ។ រាល់ការអះអាងដែលបានចោទប្រកាន់ទាំងអស់របស់មេធាវីការពារក្ដី គឺចូលនៅក្នុងប្រភេទនៃសេចក្ដីសម្រេចទាំងឡាយដែលនៅសេសសល់ដែលត្រូវតែប្ដឹងសាទុក្ខ ប្រសិនបើមាន "គឺធ្វើនៅចំពេល ោធ្វើបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើអង្គសេចក្ដី"[8]។

៧- បន្ថែមទៅលើការអះអាងរបស់មេធាវីការពារក្ដី គឺមិនអាចប្ដឹងសាទុក្ខភ្លាមៗបានទេ ដោយផ្អែកទៅតាមវិធានផ្ទៃក្នុង និងយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះនេះ ការអះអាងជាច្រើន គឺមិនទាន់ដល់ពេលសម្រាប់ធ្វើការពិនិត្យឡើងវិញនៅឡើយនោះទេ។ ឧទាហរណ៍ មេធាវីការពារក្ដីបានលើកឡើងនូវអំណះអំណាងទូលំទូលាយជាច្រើន ដែលបញ្ជាក់អំពីកំហុសឆ្គងទាក់ទងទៅនឹងការរកឃើញអំពីសហកម្មឧក្រិដ្ឋកម្មរួមដែលពួកគេរំពឹងទុកជាមុនថាអង្គជំនុំជម្រះសាលាដំបូង មុខជានឹងធ្វើនៅក្នុងសាលក្រមក្នុងសំណុំរឿងលេខ០០២/០១ ក៏ដូចជា អានុភាពដែលពួកគេបានធ្វើសម្មតិកម្មចំពោះការរកឃើញទាំងនោះថា នឹងមានចំពោះការជំនុំជម្រះក្ដីណាមួយជាបន្តបន្ទាប់ទៅទៀតនៅក្នុងសំណុំរឿងលេខ០០២។ មេធាវីការពារក្ដីបានគិតស្មានៗថា៖ "អង្គជំនុំជម្រះសាលាដំបូងទីពីររួមមានសមាសភាពនៃចៅក្រមថ្មីៗទៀត នឹងធ្វើការកំណត់សម្រេចអំពីតួនាទីរបស់ជនជាប់ចោទនៅក្នុង "ការអនុវត្ត" នូវគោលនយោបាយដែលនៅសេសសល់ចំនួនបីទៀត"[9]។ ហើយថា "មានការលំបាកមើលឱ្យឃើញថា តើចៅក្រមថ្មីនៃអង្គជំនុំជម្រះនឹងធ្វើការកំណត់សម្រេចយ៉ាងដូចម្ដេច អំពីការទទួលខុសត្រូវរបស់ជនជាប់ចោទ ទាក់ទងនឹងឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់នៅការជំនុំជម្រះក្ដីវគ្គទីពីរ ដោយផ្អែក

---

[7] ឯកសារលេខ **E154/1/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការប្រាស្រ័យទាក់ទងការងារជាមួយតែភាគីម្ខាងរបស់មន្ត្រីច្បាប់ជាន់ខ្ពស់, ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២, ត្រង់កថាខណ្ឌទី១២។ (ការសង្កត់ន័យបន្ថែមដោយអក្សរទ្រេត, ការលើកសម្អាងផ្ទៃក្នុងត្រូវបានរំលងចោល)។

[8] វិធាន១០៤ នៃវិធានផ្ទៃក្នុង។

[9] ឯកសារលេខ **E275/2/1/1** សំណើ, ត្រង់កថាខណ្ឌទី ៤៦។

លើមូលដ្ឋាននៃការគិតដោយស្មានៗថា គោលនយោបាយនានាដែលបាននាំឲ្យឧក្រិដ្ឋកម្មទាំងនេះកើតមានឡើង នឹងត្រូវបានធ្វើការកំណត់សម្រេចរួចហើយដោយអង្គជំនុំជម្រះបច្ចុប្បន្ននេះនៅក្នុងសំណុំរឿងលេខ០០២/០១"[10]។ អាចជាការមិនទាន់ដល់ពេល និងការប្រើប្រាស់មិនមានប្រសិទ្ធភាពនូវធនធានមានកម្រិតរបស់តុលាការនេះ សម្រាប់អង្គជំនុំជម្រះនេះក្នុងការពិនិត្យពិចារណាទៅលើការអះអាងនានាដែលជំទាស់ទៅនឹងអ្វី ដែលអង្គជំនុំជម្រះសាលាដំបូង <u>អាច</u> នឹងសម្រេចនៅក្នុងសាលក្រមរបស់ខ្លួន នៅពេលដែលអង្គជំនុំជម្រះនេះមានឱកាសដើម្បីធ្វើការពិចារណាទៅលើអំណះអំណាងនានា នៅក្នុងបណ្តឹងសាទុក្ខចំពោះសាលក្រមដោយផ្អែកលើមូលដ្ឋានអ្វីដែល<u>ជាក់ស្តែង</u>អង្គជំនុំជម្រះសាលាដំបូងបានសម្រេច។ ដូចគ្នានេះដែរ អំណះអំណាងទាំងឡាយដែលទាក់ទងទៅនឹងការអះអាងអំពីការគិតដោយស្មានៗ ពាក់ព័ន្ធនឹងសេចក្តីសម្រេចដែលអាចនឹងត្រូវបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿងលេខ០០២/០២ ដែលនឹងត្រូវបញ្ជូនទៅជំនុំជម្រះ[11] គួរបានលើកឡើង តែក្នុងករណី និងនៅពេលណាដែលមានមូលដ្ឋានរឹងមាំតែប៉ុណ្ណោះ។

## គ. ការដាក់សំណើនេះ មិនអាចទទួលយកបានទេ អនុលោមតាមយុត្តិសាស្ត្រ ដែលមេធាវីការពារក្តីបានលើកយកមកសម្អាង

៨- ជាជាងការព្យាយាមលើកសម្អាងណាមួយដែលថា ការដាក់សំណើរបស់ពួកគេបានបំពេញទៅតាមបទដ្ឋានសម្រាប់ភាពអាចទទួលយកបានដែលបានចែងដោយវិធាននៃផ្ទៃក្នុង ឬដោយយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះនេះ មេធាវីការពាក្តីបានព្យាយាមពឹងផ្អែកលើយុត្តិសាស្ត្រមិនត្រឹមត្រូវ ដែលមកពីអង្គបុរេជំនុំជម្រះ តុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការពិសេសសម្រាប់ប្រទេសលីបង់ ទៅវិញ។ បន្ថែមពីលើយុត្តិសាស្ត្រដែលបានលើកយកមកយោង ដែលមិនមានការជាប់ទាក់ទងសោះឡើយដោយសារការពន្យល់ច្បាស់លាស់របស់អង្គជំនុំជម្រះនេះអំពីបទដ្ឋានសម្រាប់ភាពអាចទទួលយកបាន នៅចំពោះមុខខ្លួន មេធាវីការពារក្តីខកខានផងដែរ ក្នុងការបំពេញទៅតាមបទដ្ឋាននានានៃយុត្តិសាស្ត្រដែលបានលើកជាសម្អាងនោះ។

---

[10] ឯកសារលេខ **E275/2/1/1** សំណើ, ត្រង់កថាខណ្ឌទី ៥០។

[11] ឯកសារលេខ **E275/2/1/1** សំណើ, ត្រង់កថាខណ្ឌទី ៣៨ (ការធ្វើអំណះអំណាងដែលទាក់ទងទៅនឹង "វគ្គនៃសវនាការជំនុំជម្រះក្តីនីមួយៗជាបន្តបន្ទាប់មកទៀត")។ *ដូចគ្នានឹងខាងលើ*, ត្រង់កថាខណ្ឌទី៤១ (ការធ្វើអំណះអំណាងដែលទាក់ទងទៅនឹង "វគ្គនៃសវនាការជំនុំជម្រះក្តីនីមួយៗជាបន្តបន្ទាប់មកទៀត")។

៩- អង្គបុរេជំនុំជម្រះ ដោយបានធ្វើការបកស្រាយវិធានខុសគ្នាទាំងស្រុងទៅនឹងវិធាន១០៤(៤) បានរកឃើញថា "បើសិនជាអង្គហេតុ និងកាលៈទេសៈនានានៃបណ្តឹងសាទុក្ខ តម្រូវឲ្យ... នោះខ្លួនមានសមត្ថកិច្ច ដើម្បីពិចារណាលើទឡ្ហីករណ៍ដែលបានលើកឡើងដោយម្ចាស់បណ្តឹងសាទុក្ខដែលមិនបានរៀបរាប់ច្បាស់លាស់នៅក្នុងវិធាន ៧៤(៣) តាមរយៈការបកស្រាយដោយសេរី ចំពោះសិទ្ធិជនត្រូវចោទណាម្នាក់ ដើម្បីបណ្តឹងសាទុក្ខ តាមស្មារតីនៃវិធាន២១"[12]។ ដោយបានលើកយោងការសម្រេចនេះ ទោះបីជាយ៉ាងណាក៏ដោយ មេធាវីការពារក្តីខកខានមិនបានជូនដំណឹងជាមុនដល់អង្គជំនុំជម្រះតុលាការកំពូល អំពីការកម្រិតសំខាន់ៗនៃសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដោយគ្រាន់តែមានពីរបីប្រយោគប៉ុណ្ណោះនាពេលក្រោយមក៖

> អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា ... ខ្លួនមិនបានសម្រេចថា យោងតាមវិធានទូទៅមួយ ខ្លួនមិនមានសមត្ថកិច្ចដោយស្វ័យប្រវត្តិតាមវិធាន៧៤(៣) ឬវិធាន២១ ដើម្បីពិចារណាលើទឡ្ហីករណ៍ណាមួយនៃបណ្តឹងសាទុក្ខ ដែលក្នុងនោះ ម្ចាស់បណ្តឹងសាទុក្ខបានលើកពីបញ្ហានានា ដែលជាប់ពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីនោះទេ។ ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះបានពិចារណាយ៉ាងប្រុងប្រយ័ត្នលើគ្រប់ករណីនិមួយៗ ដោយមានការថ្លឹងថ្លែងគ្រប់បែបយ៉ាង ថាតើ "អង្គហេតុ និងកាលៈទេសៈនានា" នៃបណ្តឹងសាទុក្ខនោះ តម្រូវឲ្យមានការបកស្រាយទូលំទូលាយមួយអំពីសិទ្ធិប្តឹងសាទុក្ខដែរ ឬអត់[13]។

១០- បន្ទាប់មក អង្គបុរេជំនុំជម្រះ បានធ្វើការសន្និដ្ឋានថា ទាក់ទងនឹងបណ្តឹងសាទុក្ខដែលកំពុងលើកឡើងនេះ គឺជាផលប្រយោជន៍នៃកិច្ចដំណើរការនីតិវិធីធ្វើយ៉ាងណាឲ្យប្រព្រឹត្តិទៅបានឆាប់រហ័ស មានទម្ងន់ធ្ងន់ជាងផលប្រយោជន៍នៃការទទួលយកបានចំពោះបណ្តឹងសាទុក្ខនេះ[14]។ អង្គបុរេជំនុំជម្រះបានធ្វើការកត់សម្គាល់យ៉ាងដូច្នេះថា៖ ... មាត្រា៣៣ថ្មី នៃច្បាប់ អ.វ.ត.ក ចែងថា "អង្គជំនុំជម្រះវិសាមញ្ញនេះ ត្រូវធានាថាការជំនុំជម្រះត្រូវយុត្តិធម៌ *និងឆាប់រហ័ស*"។ លើសពីនេះ វិធាន២១(៤)

[12] **D427/2/15** សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៥ កុម្ភៈ ២០១១ (ចាប់ពីនេះតទៅហៅថា "សាលដីការបស់ អបជ"), ត្រង់កថាខណ្ឌទី៧១។ *សូមមើលផងដែរ* **D264/2/6** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលបដិសេធសំណើសុំការផ្អាកកិច្ចដំណើរការនីតិវិធី ដោយផ្អែកលើការបំពានដំណើរការ (ឯកសារលេខ២៦៤/១), ១០ សីហា ២០១០, ត្រង់កថាខណ្ឌទី១៤។

[13] **D427/2/15** សាលដីការបស់ អបជ, ត្រង់កថាខណ្ឌទី៧៣ (សេចក្តីយោងខាងក្នុងត្រូវបានលុបចេញ)។

[14] **D427/2/15** សាលដីការបស់ អបជ, ត្រង់កថាខណ្ឌទី៧៤។

ចែងពីគោលការណ៍ជាមូលដ្ឋានដែលអនុវត្តដោយ អ.វ.ត.ក គឺថា "កិច្ចដំណើរការនីតិវិធីត្រូវបញ្ចប់នៅក្នុងរយៈពេលមួយសមស្រប"។ ស្រដៀងគ្នានេះ មាត្រា១៤(៣) នៃអនុសញ្ញា ICCPR ដែលបានឆ្លុះបញ្ចាំងតាមរយៈវិធាន២១ចែងថា "ក្នុងការកំណត់អំពីបទចោទព្រហ្មទណ្ឌណាមួយប្រឆាំងនឹងជនណាម្នាក់ ជននោះត្រូវមានសិទ្ធិទទួលបានការធានាជាអប្បបរមាដូចតទៅ... គ) ទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលមិនត្រឹមត្រូវ"[15]។

១១- ផ្នែកផ្សេងទៀត អង្គបុរេជំនុំជម្រះបានធ្វើការកត់សម្គាល់ថា "ផលប្រយោជន៍នៃការអភិរក្សធនធានតុលាការ និងការបង្កើនល្បឿននៃដំណើរការច្បាប់ និងនីតិវិធី" គឺពាក់ព័ន្ធផងដែរនឹងការពិនិត្យពិចារណា[16]។ នៅក្នុងការសម្រេចដូច្នេះ ផលប្រយោជន៍ទាំងនេះ "ត្រូវតែធំជាង និងមានទម្ងន់ជាងផលប្រយោជន៍នៃការទទួលបានការពិនិត្យពិចារណាលើទឡ្ហីករណ៍នានានៃបណ្តឹងសាទុក្ខ នៅក្នុងដំណាក់កាលនេះ"[17] ហើយអង្គបុរេជំនុំជម្រះ ក៏បានធ្វើការកត់សម្គាល់ផងដែរថា អំណះអំណាងទាំងឡាយដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខនោះ ក៏អាចលើកឡើងនៅពេលក្រោយបាន[18]។

១២- ហេតុដូច្នេះ សូម្បីតែនៅក្រោមករណីយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ "អង្គហេតុ និងកាលៈទេសៈនានា" ផ្តល់ដំបូន្មានប្រឆាំងនឹងការទទួលយក ដោយសារផលប្រយោជ៏នៃភាពឆាប់រហ័ស ការប្រើប្រាស់ធនធានផ្សេងៗឲ្យបានហ្មត់ចត់ និងលទ្ធភាពនៃការលើកឡើងនូវការទាមទារនៅពេលក្រោយ ដែលជាការដាស់តឿនចំពោះការផ្តល់ការអនុញ្ញាតក្នុងការទទួលយក ដូចដែលគេបានធ្វើនៅទីនេះដែរ បណ្តឹងសាទុក្ខនឹងត្រូវបានចាត់ទុកថាមិនអាចទទួលយកបាន។

១៣- លើសពីនេះ អង្គជំនុំជម្រះខ្លួនឯងនេះ ក៏ធ្លាប់បានលើកអំពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះបានសម្រេចថាមេធាវីការពារក្តីរិះរកចុះបញ្ជីនៅទីនេះដែរ ដោយបានធ្វើការកត់សម្គាល់អំពីវិសាលភាពមានកម្រិតរបស់ខ្លួន ដោយបានបញ្ជាក់ថា៖

---

[15] **D427/2/15** សាលដីការបស់ អបជ, ត្រង់កថាខណ្ឌទី៧៤ (សេចក្តីយោងខាងក្នុងត្រូវបានលប់ចេញ; សង្កត់ន័យដើម)។

[16] **D427/2/15** សាលដីការបស់ អបជ, ត្រង់កថាខណ្ឌទី៧៣, ដកស្រង់ឯកសារ **D97/15/9** សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម, ២០ ឧសភា ២០១០, ត្រង់កថាខណ្ឌទី៣៤, ៣៥។

[17] **D427/2/15** សាលដីការបស់ អបជ, ត្រង់កថាខណ្ឌទី៧៦។

[18] **D427/2/15** សាលដីការបស់ អបជ, ត្រង់កថាខណ្ឌទី៧៦។

អង្គបុរេជំនុំជម្រះពីមុនធ្លាប់សម្រេចថា វិធាន២១ តម្រូវឲ្យខ្លួន "ធ្វើការបកស្រាយវិធានផ្សេងៗនានា ទៅតាមមធ្យោបាយមួយដែលថា បណ្តឹងសាទុក្ខក៏អាចទទួលយកបានទៅតាមមូលដ្ឋាននៃវិធាន២១"។ ប៉ុន្តែ អង្គបុរេជំនុំជម្រះ បានធ្វើការអធិប្បាយពីសេចក្តីសម្រេចនេះថាជា "ការបកស្រាយមួយដោយសេរីអំពីសិទ្ធិនៃការធ្វើបណ្តឹងសាទុក្ខ តាមស្មារតីនៃវិធាន២១" និងមិនមែនជាវិធានទូទៅដែលប្រគល់សមត្ថកិច្ចលើបណ្តឹងសាទុក្ខ ទៅលើបញ្ហាណាមួយដែលជាប់ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីនោះទេ។ ផ្ទុយទៅវិញ ការទទួលយកបណ្តឹងសាទុក្ខណាមួយក្រោមវិធាន២១ ត្រូវបានពិចារណាថា ជាករណីលើកលែង គឺពាក់ព័ន្ធតែករណីដែលអង្គហេតុ និងកាលៈទេសៈពិសេសនានា តម្រូវឲ្យមានការបកស្រាយទូលំទូលាយជាងនេះអំពីសិទ្ធិនៃការប្តឹងសាទុក្ខប៉ុណ្ណោះ[19]។

១៤- ការសំខាន់ អង្គជំនុំជម្រះនេះបានកត់សម្គាល់បន្ថែមទៀតនៅក្នុងការវាយតម្លៃរបស់ខ្លួន ចំពោះករណីយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះថា "គេគ្មានសិទ្ធិជាទូទៅដើម្បីធ្វើបណ្តឹងសាទុក្ខបន្ទាន់ភ្លាមៗ ដែលអាចនឹងត្រូវបានកាត់បន្ថយដោយសារយុត្តិសាស្ត្រចង្អៀតតាមវិធាន១០៤(៤)"[20] នោះឡើយ។

១៥- ក្នុងសេចក្តីសម្រេចក្នុងរឿងក្តី *Lubanga* ពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបានលើកយោងដោយមេធាវីការពារក្តី គឺមិនពាក់ព័ន្ធទេ ដោយហេតុថា វាមិនពាក់ព័ន្ធនឹងការទទួលយក ប៉ុន្តែពាក់ព័ន្ធនឹងដំណោះស្រាយ។ បញ្ហានៃការទទួលយកនៅក្នុងសេចក្តីសម្រេចនោះ ត្រូវបានសម្រេចទៅតាមអង្គហេតុពិតដែលថា រដ្ឋអាជ្ញាបានដាក់ពាក្យសុំទៅអង្គជំនុំជម្រះសាលាដំបូង ហើយក៏បានទទួលនូវការអនុញ្ញាតឲ្យប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលសម្រេចឲ្យផ្អាកកិច្ចដំណើរការនីតិវិធី[21]។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នោះ អំពីដំណោះ

---

[19] **E154/1/1/4** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការប្រាស្រ័យទំនាក់ទំនងតែម្នាងរបស់មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់របស់ខ្លួន, ២៥ មេសា ២០១២, ត្រង់កថាខណ្ឌទី១៤ (សេចក្តីយោងខាងក្នុងត្រូវបានលប់ចេញ)។

[20] **E154/1/1/4** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការប្រាស្រ័យទំនាក់ទំនងតែម្នាងរបស់មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់របស់ខ្លួន, ២៥ មេសា ២០១២, ត្រង់កថាខណ្ឌទី១៥។

[21] *រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo*, សំណុំរឿងលេខ: ICC-01/04-01/06 OA 13, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង I ដែលមានចំណងជើងថា "សេចក្តីសម្រេចអំពីផលវិបាកផ្សេងៗនៃការមិនបង្ហាញសម្ភារៈដោះបន្ទុកដូចបានរៀបរាប់នៅក្នុងមាត្រា ៥៤(៣)(ង) នៃកិច្ចព្រមព្រៀង និងការអនុវត្តចំពោះការផ្អាកការចោទប្រកាន់ជន

ស្រាយ គឺមិនពាក់ព័ន្ធទេ។ យ៉ាងណាក៏ដោយ គេគួរកត់សម្គាល់ថា អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានធ្វើការបកស្រាយស្រដៀងគ្នា អំពីអំណាចរបស់ខ្លួនចំពោះការកំណត់ "ការផ្អាកកិច្ចដំណើរការនីតិវិធី" នៅក្នុងអង្គជំនុំជម្រះដែលមានភាពចង្អៀត ហើយដែលចាំបាច់នៅក្នុង "កាលៈទេសៈនៃករណីរឿងក្តី"[22] ដែលថា "គេគ្មានការសង្ឃឹមថា នឹងមានសវនាការជំនុំជម្រះមួយដែលត្រឹមត្រូវទេ"[23] ដោយសារតែបុរេលក្ខខណ្ឌសំខាន់ៗនៃការជំនុំជម្រះដែលត្រឹមត្រូវនោះ កំពុងតែបាត់បង់ ហើយដែលគ្មានសញ្ញាគ្រប់គ្រាន់ណាមួយដែលគេនឹងអាចដោះស្រាយបញ្ហានេះបាននៅក្នុងអម្លុងពេលនៃដំណើរការសវនាការជំនុំជម្រះនោះ[24]។

១៦- សំខាន់ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Lubanga* ខ្លួនឯងផ្ទាល់បានឈានដល់ការកំណត់មួយថា ការជំនុំជម្រះត្រឹមត្រូវមួយមិនអាចធ្វើទៅបាន ហើយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនោះដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានបញ្ជាក់ និងបានផ្តល់ "ការលើកសរសើរពីគុណតម្លៃមានកម្រិត ដោយផ្អែកលើការយល់ដឹងផ្ទាល់ខ្លួនពីដំណើរការរហូតមកដល់ពេលនេះ ចំពោះកាលៈទេសៈអំពីថាតើ និងនៅពេលណា ដែលលក្ខខណ្ឌតម្រូវនៃការផ្អាកកិច្ចដំណើរការនីតិវិធី សមទទួលបានការផ្អាកកិច្ចដំណើរការនីតិវិធី"[25]។ ចំពោះសំណើភ្លាមៗនេះ អង្គជំនុំជម្រះសាលាដំបូងមិនបានរកឃើញទេ ដែលថាការផ្អាកកិច្ចដំណើរការនីតិវិធីត្រូវធានានោះ។

១៧- នៅក្នុងសេចក្តីសម្រេចធ្វើឡើងដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការពិសេសសម្រាប់ប្រទេសលីបង់ ដែលមេធាវីការពារក្តីបានលើកយោង អង្គជំនុំជម្រះពិតជាបានប្រើ "យុត្តិសាស្ត្រដែលមានជាប់មកជាមួយ"ប្រាកដមែន ដើម្បីពិចារណាលើបណ្តឹងសាទុក្ខភ្លាមៗ[26] ប៉ុន្តែការសម្រេចនោះផ្ទុយស្រឡះពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនេះ ដែលមិនទទួលស្គាល់យុត្តិសាស្ត្រជាប់មកជាមួយ សម្រាប់បណ្តឹងសាទុក្ខភ្លាមៗដែលស្ថិតនៅក្រៅវិធាន១០៤(៤)។ លើសពីនេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បាន

---

ជាប់ចោទ រួមជាមួយនឹងបញ្ហាជាក់លាក់ផ្សេងទៀតដែលបានលើកឡើងនៅឯសន្និបាតកាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៨", (ចាប់ពីនេះតទៅហៅថា "សេចក្តីសម្រេចក្នុងរឿងក្តី Lubanga" ត្រង់កថាខណ្ឌទី៧។

[22] សេចក្តីសម្រេចក្នុងរឿងក្តី Lubanga" ត្រង់កថាខណ្ឌទី៧៥។

[23] សេចក្តីសម្រេចក្នុងរឿងក្តី Lubanga" ត្រង់កថាខណ្ឌទី៧៥។

[24] សេចក្តីសម្រេចក្នុងរឿងក្តី Lubanga" ត្រង់កថាខណ្ឌទី៧៦។

[25] សេចក្តីសម្រេចក្នុងរឿងក្តី Lubanga" ត្រង់កថាខណ្ឌទី៨៥។

[26] តុលាការពិសេសសម្រាប់ប្រទេសលីបង់, សំណុំរឿងលេខៈ CH/AC/2010/02, សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ចៅក្រមអង្គបុរេជំនុំជម្រះទាក់ទិននឹងយុត្តិសាស្ត្រ និងសិទ្ធិប្តឹង, ១០ វិច្ឆិកា ២០១០ (ចាប់ពីនេះតទៅហៅថា "សាលដីកាក្នុងរឿងក្តី STL", ត្រង់កថាខណ្ឌទី៥៤។

ធ្វើការកត់សម្គាល់ថា ការប្រើយុត្តិសាស្ត្រដូច្នេះ គឺជាករណីលើកលែងកម្រមួយ ដោយបានថ្លែងដូច្នេះថា៖ "អង្គជំនុំជម្រះសាលាឧទ្ធរណ៍ជាធម្មតាមិនធ្វើការពិចារណាលើបណ្តឹងសាទុក្ខភ្លាមៗ ដែលស្ថិតនៅក្រៅវិធានផ្ទៃក្នុងឡើយ..."[27]។ ខ្លួនមានបំណងធ្វើការលើកលែងដូច្នេះ បើសិនជាមាន "សភាពការណ៍ណាមួយបានកើតឡើងដោយសារវិធានផ្ទៃក្នុងពុំបានគិតទុកជាមុន ហើយបើសិនជាមានការចោទប្រកាន់ថាកំហុសយុត្តាធិការត្រូវបានធ្វើឡើង ហើយភាពអយុត្តិធម៌អាចកើតឡើងប្រសិនបើកំហុសដូចដែលគេបានចោទប្រកាន់នោះ ត្រូវបានទុកចោលដោយគ្មានការកែតម្រូវ"[28]។ ផ្ទុយទៅវិញ សំណើភ្លាមៗនេះមិនបានឆ្លើយតបចំពោះប្រភេទណាមួយក្នុងចំណោមប្រភេទទាំងបីនេះទេ។ វិធាននេះពិតជាបានប្រមើលមើលពីប្រភេទនៃបណ្តឹងទាមទារ ដូចដែលមេធាវីការពារក្តីបានលើកឡើងនៅទីនេះ ហើយបានកំណត់ថា ការទាមទារនោះគប្បីប្តឹងសាទុក្ខបានតែនៅក្រោយពេលមានសាលក្រមលើអង្គសេចក្តីប៉ុណ្ណោះ។ ការទាមទាររបស់មេធាវីការពារក្តីមិនបានលើកអំពីយុត្តាធិការ ឬបញ្ហាស្នូលនានាដែលស្រដៀងគ្នានេះទេ។ ហើយភាពអយុត្តិធម៌នឹងមិនកើតឡើង ប្រសិនបើកំហុសដូចដែលបានចោទប្រកាន់នោះ មិនត្រូវបានដោះស្រាយនៅក្នុងពេលនេះ ដោយសារកំហុសទាំងនោះអាចត្រូវបានដោះស្រាយ តាមរយៈបណ្តឹងសាទុក្ខបន្ទាប់ពីមានសាលក្រមលើអង្គសេចក្តី ឬនៅក្នុងអម្លុងនៃសវនាការជំនុំជម្រះជាបន្តបន្ទាប់ណាមួយនៅក្នុងសំណុំរឿង០០២។ ហេតុដូច្នេះ គេគ្មានមូលហេតុដើម្បីដើរចេញពីយុត្តិសាស្ត្រសម្រាប់ធ្វើបណ្តឹងសាទុក្ខភ្លាមៗជាធម្មតា នៅក្នុងវិធានផ្ទៃក្នុងដែលមានចែងពីកាលៈទេសៈផ្សេងៗទាំងនោះឡើយ។

## ឃ. មេធាវីការពារក្តី មិនគោរពចំពោះអង្គជំនុំជម្រះសាលាដំបូង

១៨- សហព្រះរាជអាជ្ញារំលឹកថា "ច្បាប់កម្ពុជាតម្រូវឲ្យមេធាវីការពារក្តីដែលមានវត្តមាននៅចំពោះមុខ អ.វ.ត.ក ត្រូវ "សំដែងជូនចៅក្រមក្នុងលក្ខណៈឯករាជ្យ និងភាពថ្លៃថ្នូរ ការគោរពទៅតាមមុខងាររបស់គេ"[29]។ តាមទស្សនៈរបស់សហព្រះរាជអាជ្ញា មេធាវីការពារក្តីបានរំលោភលើកាតព្វកិច្ចនេះ នៅក្នុងដំណើរនៃការធ្វើសំណើសុំរបស់ខ្លួន មេធាវីការពារក្តីអះអាងថា អង្គជំនុំជម្រះសាលាដំបូងបាននិយាយ "កុហក"[30] ដែលថា "ចាប់តាំងពីពេលចាប់ផ្តើមមក អង្គជំនុំជម្រះមិនដែលដឹកនាំឲ្យមាន

---

[27] សាលដីកាក្នុងរឿងក្តី STL, ត្រង់កថាខណ្ឌទី៥៤។

[28] សាលដីកាក្នុងរឿងក្តី STL, ត្រង់កថាខណ្ឌទី៥៤។

[29] **E214** សេចក្តីសម្រេចអំពីកំហុសវិជ្ជាជីវៈមេធាវីការពារក្តី នួន ជា, ២៩ មិថុនា ២០១២, ត្រង់កថាខណ្ឌទី៨។

[30] **E275/2/1/1** សំណើ, ត្រង់កថាខណ្ឌទី៥៨។

ការជំនុំជម្រះមួយដែលត្រឹមត្រូវទេ”[31] និងថាពេលនេះគេមានភស្តុតាងបញ្ជាក់ថា អង្គជំនុំជម្រះមិនចង់ផ្តល់ឲ្យលោក ខៀវ សំផន នូវមធ្យោបាយ ដើម្បីការពារខ្លួនគាត់ និងស្តាប់សវនាការពីគាត់ទេ”[32] និងអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានភាពលម្អៀង[33] ថា អង្គជំនុំជម្រះសាលាដំបូង “មិនមានទាំងសមត្ថភាព និងចេតនា ក្នុងការធ្វើសវនាការមួយដែលត្រឹមត្រូវនោះទេ”[34]។

## III. សេចក្តីសន្និដ្ឋាន

១៩- ដូចមូលហេតុដែលបានរៀបរាប់ខាងលើ សហព្រះរាជអាជ្ញា ស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូល **ច្រានចោល** សំណើនេះទាំងស្រុង៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY សហព្រះរាជអាជ្ញា | | [signature] |

[31] **E275/2/1/1** សំណើ, ត្រង់កថាខណ្ឌទី៦៨។

[32] **E275/2/1/1** សំណើ, ត្រង់កថាខណ្ឌទី៦៩។

[33] **E275/2/1/1** សំណើ, ត្រង់កថាខណ្ឌទី៨៩។

[34] **E275/2/1/1** សំណើ, ត្រង់កថាខណ្ឌទី១០២។